


# តើយើងអធិស្ឋានដោយរបៀបណា ?

ការអធិស្ឋានគឺជារបៀបដែលយើងនិយាយជាមួយព្រះវរបិតាសួគ៌ ។ ទ្រង់តែងតែចង់ស្តាប់ពីអ្នក ហើយទ្រង់តែងតែស្តាប់អ្នកជានិច្ច ។ ទ្រង់ឆ្លើយតបនឹងការអធិស្ឋានរបស់អ្នកតាមរបៀបជាច្រើន ។ ទ្រង់នឹងប្រទានដល់អ្នកនូវការបំផុសគំនិត ឬអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។ ឬទ្រង់អាចបំផុសគំនិតឲ្យនរណាម្នាក់ជួយអ្នក ។

## របៀបដើម្បីអធិស្ឋាន

បិទភ្នែក ឱនក្បាល ហើយឱបដៃរបស់អ្នក ។

ចាប់ផ្តើមដោយពោលថា « ឱព្រះវរបិតាសួគ៌ជាទីស្រឡាញ់ » ។

ចូរនិយាយទៅកាន់ព្រះវរបិតាសួគ៌ ដោយការគោរព និងគារវភាព ។

បញ្ចប់ដោយពោលថា « នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទអាម៉ែន » ។

អ្នកអាចអធិស្ឋានខ្លាំងៗ ឬអធិស្ឋានក្នុងចិត្តរបស់អ្នក នៅពេលណាក៏បាន ។

## នេះគឺជាអ្វីមួយដែលអ្នកអាចអធិស្ឋានអំពី ៖

សូមអរព្រះគុណព្រះវរបិតាសួគ៌ចំពោះអ្វីដែលអ្នកមានអំណរគុណ ។

សូមទូលប្រាប់ទ្រង់អំពីរឿងពិបាក ឬរឿងល្អៗដែលបានកើតឡើងនៅថ្ងៃនេះ ។

សូមជំនួយពីទ្រង់ពេលអ្នកភ័យខ្លាច ឬមិនដឹងថាត្រូវធ្វើអ្វី ។

សូមឲ្យទ្រង់ប្រទានពរដល់អ្នកឯទៀតដែលត្រូវការជំនួយ ។